ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦

**សេចក្តីផ្តើម** :

នៅក្នុងឆមាសទី១នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមនេះ

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**:

**១.មុខងារនីតិកម្ម**:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៩លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៥លើក និងប្រជុំវិសាមញ្ញចំនួន០១លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់<br>- បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងតំណាងរដ្ឋសភាចំនួន០៥លើក ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៦<br>- ប្រជុំគណៈកម្មការពិសេសចំនួន០៥លើក ដើម្បីពិនិត្យពិភាក្សាលើសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក | - រៀបចំទីកន្លែង ចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គ ប្រជុំវិសាមញ្ញ ប្រជុំអន្តរគណៈកម្មការ និងគណៈកម្មការពិសេសចំនួន២៥លើក<br>- បានផ្គត់ផ្គង់សម្ភារ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗចំនួន២៩លើក មានអ្នកចូលរួមចំនួន១,៨៨២នាក់<br>- បានដោះស្រាយសំណើនានា ជូនព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៧៤លើក<br>- ថតចម្លងឯកសារបានចំនួន៣២សំណើ និងធ្វើជាសៀវភៅចំនួន២០២ក្បាល អស់ក្រដាសចំនួន១១២,៨០៥សន្លឹក |

| | |
|---|---|
| ព្រឹទ្ធសភា និងសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា ។ | - ផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានី ជូនមន្ត្រីរាជការព្រឹទ្ធសភាចំនួន២១នាក់ ស្មើនឹង០៦លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំផ្សេងៗ ចំនួន៧៧នាក់ និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នមានចំនួន៣១៥នាក់<br>- បានធ្វើសេចក្តីសម្រេច និងផ្សព្វផ្សាយ ស្តីពីការទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី និងសេចក្តីសម្រេចស្តីពីការចាត់តាំង និងកែសម្រួលសមាសភាពក្រុមសមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគ<br>- ប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យសិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងសេចក្តីស្នើបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាសម្រាប់នីតិកាលទី៤ និងសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់ពីរដ្ឋសភា និង១០ច្បាប់ពីរាជរដ្ឋាភិបាល ព្រមទាំងបានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរ និងលិខិតផ្សេងៗ ចំនួន១,១៣២ ពីក្រសួងស្ថាប័ននានា និងបានចាត់ចែងតាមនីតិវិធី<br>- បន្តធ្វើបច្ចុប្បន្នភាពបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងបន្តសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីសេចក្តីព្រាងច្បាប់ចំនួន២០ច្បាប់ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន៣៩ប្រធានបទ<br>- បន្តធ្វើការចងក្រងឯកសារព័ត៌មានបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធប្រចាំខែមេសា-មិថុនា ឆ្នាំ២០១៦ |

| | |
|---|---|
| - | ចំនួន០៥ច្បាប់<br>- ថតសម្លេង និងរូបភាពវីដេអូ ផ្សព្វផ្សាយព័ត៌មានចំនួន៤៤លើក បង្ហោះលើគេហទំព័រព្រឹទ្ធសភា និងផលិតជា Video Online ចំនួន១៦,១៤៩លើក និងបានរៀបចំប្រព័ន្ធម៉ៃក្រូហ្វូនចំនួន២៨៤លើក ព្រមទាំងបានបំពាក់ម៉ៃក្រូហ្វូនថ្មី និងម៉ាស៊ីនថតសម្លេងចំនួន០៤ឈុត/គ្រឿង ។ |

**២.មុខងារតំណាង** :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ថ្នាក់ដឹកនាំព្រឹទ្ធសភា បានចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះព្យាបាលជំងឺ ចែកអំណោយជូនប្រជាពលរដ្ឋដែលជួបទុក្ខលំបាក រំលែកទុក្ខដល់ក្រុមគ្រួសារសព នាំយកបច្ច័យ និងទេយ្យវត្ថុទៅវេរប្រគេនព្រះសង្ឃ បង្សុកូលឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធ សម្តេចធម្មពោធិសាល ជា ស៊ីម និងលោកជំទាវ យុទ្ធជន យុទ្ធនារីដែលបានពលីជីវិត ពិនិត្យការជួសជុលហេដ្ឋារចនាសម្ព័ន្ធ ទំនប់វារីអគ្គិសនី ព្រមទាំងអញ្ជើញជាកិត្តិយស និងជាអធិបតីក្នុងពិធីផ្សេងៗចំនួន៧៣លើក នៅខេត្តកំពង់ចាម ត្បូងឃ្មុំ កណ្តាល ស្ទឹងត្រែង ពោធិ៍សាត់ បាត់ដំបង សៀមរាប ព្រៃវែង កំពត តាកែវ កំពង់ស្ពឺ និងរាជធានីភ្នំពេញ | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីភាព ក្នុងពិធីផ្លូវការផ្សេងៗ សរុបចំនួន១,០៨៦លើក<br>- រៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានធ្វើកំណត់បង្ហាញ និងបញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធ<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានស្វែងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងកម្មវិធីផ្សេងៗ<br>- បានធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ (ខេត្តតាកែវ កំពត កែប កំពង់ចាម ត្បូងឃ្មុំ បាត់ដំបង និងខេត្តព្រះសីហនុ)<br>- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ សិក្ខាសាលា |

- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត-រាជធានីទូទាំងប្រទេសចំនួន៧៥១លើក ដើម្បីសំណេះសំណាល ជួបពិភាក្សា សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន ផ្សព្វផ្សាយព័ត៌មាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗសរុបចំនួន២៦២លើក
- ថ្នាក់ដឹកនាំ ក្រុមភូមិភាគ និងសមាជិក សមាជិកាព្រឹទ្ធសភាបានយកចិត្តទុកដាក់ធ្វើសកម្មភាព ជីកអណ្ដូង ជីកស្រះ ស្ដារស្រះ នៅតាមបណ្ដាខេត្តនានា ដូចជាខេត្តកណ្ដាល ព្រៃវែង កំពង់ស្ពឺ ត្បូងឃ្មុំ កំពង់ចាម តាកែវ កំពត និងរាជធានីភ្នំពេញបានចំនួន០៨អណ្ដូង និងស្រះទឹកចំនួន១២
- ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន៤៨ករណី បញ្ជូនទៅក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន៤៦ករណី

បទបង្ហាញ ពិធីចុះហត្ថលេខា និងកិច្ចពិភាក្សាផ្សេងៗ

- សហការរៀបចំទីកន្លែងសម្រាប់វេទិកាចំនួន០៩លើក មានអ្នកចូលរួមសរុបចំនួន១,៧៦៤នាក់
- ថត និងផ្សព្វផ្សាយព័ត៌មានសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន២០៣លើក
- បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០១៦ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា
- ធ្វើលិខិតបេសកកម្មជូនសមាជិក-សមាជិកា និងមន្ត្រីរាជការព្រឹទ្ធសភាចំនួន១,០៤២នាក់ ស្មើនឹង២២៩ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន២៤នាក់ ស្មើនឹង២៤ច្បាប់
- ថតចម្លងឯកសារចំនួន៤៣សំណើ និងធ្វើជាសៀវភៅចំនួន៤៥ក្បាល អស់ក្រដាសចំនួន១១១,៤៩២សន្លឹក
- បានដោះស្រាយសំណើនានា ជូនព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៥៥លើក
- ផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងមន្ត្រីរាជការព្រឹទ្ធសភា ក្នុងរាជធានី និងចុះទៅតាមបណ្ដាខេត្តទាំង៨ភូមិភាគចំនួន១,៦០៣នាក់ ស្មើនឹង២២៧លើក
- ទទួលលិខិតចូលចំនួន៤,៦៦៩ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១,៨៣០ច្បាប់
- បានរៀបចំពិព័រណ៍សៀវភៅ និងអភិវឌ្ឍន៍ទម្ងាប់

| | |
|---|---|
| បានទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងចំនួន០៨ករណី ទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន៣៧ករណី តម្កល់ទុកមិនចាត់ការចំនួន០២ករណី កំពុងពិនិត្យសិក្សាចំនួន១៥ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន២៣នាក់<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ , ទី៤, ទី៥ , ទី៦, ទី៧ , និងទី៨ បានរៀបចំវេទិកាថ្នាក់ខេត្ត និងថ្នាក់ស្រុកចំនួន០៩លើក នៅខេត្តបន្ទាយមានជ័យ រតនគិរី បាត់ដំបង ព្រៃវែង កំពត ព្រះសីហនុ និងរាជធានីភ្នំពេញ ស្តីពីការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការអភិវឌ្ឍស្រុក-ខណ្ឌ និងភូមិ-ឃុំមានសុវត្ថិភាព លើកកម្ពស់ និងជម្រុញការអភិវឌ្ឍឃុំ-សង្កាត់ ការបង្កើនសមត្ថភាពក្រុមប្រឹក្សាឃុំក្នុងការអភិវឌ្ឍមូលដ្ឋាន សេវាសាធារណៈ "ការផ្គត់ផ្គង់ទឹកប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ ការធ្វើអត្តសញ្ញាណប័ណ្ណនិងភូមិ-ឃុំមានសុវត្ថិភាព ពិគ្រោះយោបល់ ដើម្បីផ្សព្វផ្សាយនូវសមិទ្ធផលសំខាន់ៗរបស់ព្រឹទ្ធសភា និងស្វែងយល់បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ | នៃការអានទៅបណ្ណាល័យព្រឹទ្ធសភា ដោយសហការជាមួយវិទ្យាស្ថានខុងជឺ និងបានរៀបចំពិព័រណ៍រូបភាពចំនួន៥៥សន្លឹក នៅមុខអគារក្រហម និងខាងមុខខ្លោងទ្វារធំព្រឹទ្ធសភា<br>- បានផលិតសៀវភៅទិនានុលេខន៍ឆ្នាំ២០១៦ចំនួន ៨,១០០ក្បាល ប្រតិទិនខ្នាត$A_3$ចំនួន៣៥០ច្បាប់ សារជូនពរ និងប័ណ្ណជូនពរចូលឆ្នាំខ្មែរចំនួន ១៩,៧៥០សន្លឹក ព្រឹត្តិបត្រប្រចាំខែមីនាឆ្នាំ២០១៦ ចំនួន២,៥០០ក្បាល សៀវភៅបត់ចំនួន៣៥០ច្បាប់ ជាCD ព័ត៌មានភូមិភាគទាំង៨ចំនួន៤២បន្ទះ និងបានបោះពុម្ពសៀវភៅសមិទ្ធផលព្រឹទ្ធសភា នីតិកាលទី១ ចំនួន២០០ក្បាល<br>- ផ្តល់សៀវភៅជូនមន្ទីរ ក្រសួង និងស្ថាប័ននានា ចំនួន៤៣២ក្បាល<br>- ទទួលមន្ត្រីរាជការ សិស្សនិស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១,៣០៤នាក់ ធ្វើប័ណ្ណសមាជិកចំនួន៦០នាក់ ខ្ចីសៀវភៅចំនួន៣១៤ក្បាល និងសងវិញចំនួន៣៣៥ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សានៅព្រឹទ្ធសភាចំនួន១៣លើក របស់ស្ថានទូត ក្រសួង ប្រជាពលរដ្ឋ សាស្ត្រាចារ្យ សិស្ស និងនិស្សិតសរុបចំនួន៩៤០នាក់<br>- ទទួលឯកសារសៀវភៅពីអង្គការ ស្ថានទូត ស្ថាប័ន ក្រសួង គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន ៨២៨ក្បាល ព្រឹត្តិបត្រចំនួន៧៣៨ក្បាល ទស្សនាវដ្តីចំនួន២២៩ក្បាល រាជកិច្ចចំនួន២៤៧ក្បាល |

| | |
|---|---|
| | រាជក្រមចំនួន១៥ និងផែនទីចំនួន០១<br>- ដកស្រង់ចងក្រង ផ្សព្វផ្សាយព័ត៌មានសង្ខេប និងព្រឹត្តិបត្រទស្សនព័ត៌មានប្រចាំថ្ងៃចំនួន៣២១ច្បាប់ ។ |

## ៣.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានាៈ

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - គណៈកម្មការជំនាញ បានជួបសវនាការចំនួន០៥លើក ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមុខងារសាធារណៈ និងអាជ្ញាធរសវនកម្មជាតិ<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះបេសកកម្មទៅតាមបណ្តាខេត្ត-ក្រុងនានាចំនួន១១លើក នៅខេត្តព្រះសីហនុ ស្វាយរៀង ត្បូងឃ្មុំ កំពង់ធំ ព្រះវិហារ សៀមរាប បាត់ដំបង ប៉ៃលិន មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង កណ្តាល តាកែវ និងរាជធានីភ្នំពេញ ដើម្បីសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន និងស្វែងយល់អំពីការអនុវត្តសិទ្ធិមនុស្ស និងការដោះស្រាយពាក្យបណ្តឹងរបស់ថ្នាក់ក្រោមជាតិ ការអនុវត្តច្បាប់ វឌ្ឍនភាពសំខាន់ៗ និងបញ្ហាប្រឈមនានា ពាក់ព័ន្ធជាមួយវិស័យអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ការអនុវត្តច្បាប់ស្តីពីការបង្ការ និងប្រយុទ្ធទប់ស្កាត់ការរីករាល | - ធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅសិក្សាស្វែងយល់ និងស្វែងរកព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួនចំនួន១២៣នាក់ ស្មើនឹង២០ច្បាប់<br>- បានតាមដានព័ត៌មាន សិក្សាស្រាវជ្រាវ និងធ្វើតារាងសង្ខេបស្តីពីវឌ្ឍនភាពការងាររបស់ក្រសួងស្ថាប័ននានាចំនួន១១លើក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ក្រុមសមាជិក-សមាជិកា និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានី និងតាមបណ្តាខេត្តទាំង៨ភូមិភាគចំនួន២៥នាក់ ស្មើនឹង១១លើក<br>- បានដោះស្រាយសំណើផ្សេងៗ ជូនព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៣លើក<br>- ថតចម្លងឯកសារផ្សេងៗចំនួន១៧សំណើ អស់ក្រដាសចំនួន៩,៩៤៤ សន្លឹក<br>- ថត យកព័ត៌មាន និងផ្សព្វផ្សាយសកម្មភាព របស់សមាជិក-សមាជិកាព្រឹទ្ធសភា ក្នុងកិច្ចប្រជុំជួបពិភាក្សាការងារជាមួយក្រសួងអាជ្ញាធរចំនួន៥៥លើក ។ |

| | |
|---|---|
| ដាលមេរោគអេដស៍ និងជំងឺអេដស៍ ច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជ-សាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ការអនុវត្តច្បាប់ផ្លូវថ្នល់ ច្បាប់ចរាចរណ៍ផ្លូវគោក ការផ្គត់ផ្គង់ទឹកស្អាត និងការបែងចែកអគ្គិសនី ព្រមទាំងការលើកកម្ពស់សេវាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ និងបញ្ហាប្រឈមនានា ។ | |

៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ថ្នាក់ដឹកនាំព្រឹទ្ធសភា បានអនុញ្ញាតឲ្យគណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអគ្គការអន្តរជាតិនានា ចូលជួបសម្តែងការគួរសម និងសវនាការចំនួន២០លើក<br>- សមាជិក-សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារ និងសម្តែងការគួរសមជាមួយភ្ញៀវជាតិ-អន្តរជាតិចំនួន៣០លើក<br>- ពិធីចុះហត្ថលេខាMOU និងកិច្ចព្រមព្រៀងរវាងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធនៃសហព័ន្ធរុស្ស៊ីស្តីពីការលើកកម្ពស់កិច្ចសហប្រតិបត្តិការ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអគ្គការអន្តរជាតិនានា<br>- រៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសម និងបដិសណ្ឋារកិច្ចរវាងថ្នាក់ដឹកនាំព្រឹទ្ធសភា និងភ្ញៀវអន្តរជាតិចំនួន២០លើក<br>- ថត យកព័ត៌មាន និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជួបភ្ញៀវជាតិ-អន្តរជាតិចំនួន១១លើក<br>- រៀបចំតុបតែងលម្អទីកន្លែង ទង់ជាតិ វត្ថុអនុស្សាវរីយ៍ ចាត់ចែងអ្នកបកប្រែប្រព័ន្ធផ្សព្វផ្សាយ<br>- តុបតែងលម្អ ធ្វើផ្ទាំងប៉ាណូ បដា ពាក្យស្លោក និងធ្វើហ្វុងអក្សរក្នុងពិធីផ្សេងៗចំនួន០៩លើក |

| | |
|---|---|
| អន្តរសភា<br>- សមាជិក-សមាជិកាព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ មហាសន្និបាត សន្និសីទ វេទិកា សិក្ខាសាលា និងពិធីផ្សេងៗចំនួន ១៩លើកនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាមានិតចិន ប្រទេសម៉ាឡេស៊ី សិង្ហបុរី កូរ៉េ ជប៉ុន ឥណ្ឌា ម៉ុងហ្គោលី ស៊ុយអែត ប៊ែលហ្សិក សំប៊ី កាណាដា ស៊្វីដង់ សាធារណរដ្ឋបារាំង សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ និងម៉ាដាហ្គាស្កា ។ | - រៀបចំសម្អាតសាល ផ្គត់ផ្គង់គេសជ្ជៈ សម្ភារអនាម័យក្នុងពិធីផ្សេងៗចំនួន២៧លើក មានអ្នកចូលរួមចំនួន៥៥១នាក់<br>- បានផ្គត់ផ្គង់អាហារសម្រន់សម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជួបគណៈប្រតិភូចិន និងរៀបចំជប់លៀងជូនក្រុមការងារបច្ចេកទេសចិន<br>- បានដោះស្រាយសំណើនានា ជូនព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៨៨លើក<br>- ថតចម្លងឯកសារបានចំនួន៥០សំណើ និងធ្វើជាសៀវភៅចំនួន២០ក្បាល អស់ក្រដាសចំនួន ៣៩,៩២៣សន្លឹក<br>- ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត ដើម្បីសម្រួលបែបបទ និងកម្មវិធីទស្សនកិច្ច ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត និងជំនួយស្មារតី រៀបចំបែបបទបើកបន្ទប់ពិសេស (VIP) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជូន-ទទួលដំណើរបេសកកម្មសរុបចំនួន២៥៧លើក<br>- ចេញលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការចំនួន១៥៣នាក់ ស្មើនឹង៥៦ច្បាប់ និងបញ្ជូនលិខិតទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន ២៥៥ច្បាប់<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងមន្ត្រីរាជការព្រឹទ្ធសភាក្នុងរាជធានី និងចុះទៅតាមបណ្តាខេត្តទាំង៨ភូមិភាគចំនួន ៤៩៣នាក់ ស្មើនឹង១៤៧លើក<br>- រៀបចំកញ្ចប់ដំណើរបេសកកម្មជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន១៩លើក |

| | |
|---|---|
| | - ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ជូនថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗ ដោយប្រើប្រាស់កម្លាំងសរុបចំនួន៧៦នាក់ ស្មើនឹង១៩លើក<br>- អគ្គលេខាធិការ បានជួបពិភាក្សាការងារជាមួយតំណាងស្ថានទូតជប៉ុន តំណាងភាគីក្រុមហ៊ុនចិន តំណាងមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរថ្មី និងពិធីចុះអនុស្សារណៈរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងមជ្ឈមណ្ឌលអភិវឌ្ឍកូរ៉េ សហ្វវែរ អេចអរឌី និងចុះអនុស្សារណៈ ស្តីពីកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដល់មន្ត្រីសភា ដែលជាសមាជិកសហគមន៍អន្តរសភាអាស៊ាន ព្រមទាំងបានអញ្ជើញចូលរួមប្រជុំ និងបំពេញទស្សនកិច្ចចំនួន០៤លើក នៅសាធារណរដ្ឋបារាំង ប្រទេសសំប៊ី ប៊ែលហ្ស៊ិក និងប្រទេសជប៉ុន<br>- រៀបចំបែបបទជូនមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ សន្និបាត វេទិកា សិក្ខាសាលា និងពិធីផ្សេងៗចំនួន០៧លើក នៅសាធារណរដ្ឋប្រជាមានិតចិន ប្រទេសសិង្ហបុរី ប្រទេសថៃ ប្រទេសស៊ីលី និងសាធារណរដ្ឋបារាំង<br>- ទំនាក់ទំនងជាមួយសភាវ៉ាឡូនី ព្រុចសែល ប៊ែលហ្ស៊ិក អគ្គលេខាធិការដ្ឋានរដ្ឋសភា ស្ថានទូតអូស្ត្រាលីប្រចាំប្រទេសវៀតណាម អង្គការមូលនិធិ MARC PLAN, UNESCO, SES, JDS, CIM, KAS, GIZ, ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង សមាគមអគ្គលេខាធិការនិយាយភាសាបារាំង សាលាភូមិន្ទរដ្ឋបាល ការិយាល័យអាហារូបករណ៍អូស្ត្រាលីប្រចាំកម្ពុជា វិទ្យាស្ថានខុងជឺ វិទ្យាស្ថានសភាកម្ពុជា សង្គមស៊ីវិល |

| | |
|---|---|
| | អាកាសចរណ៍ស៊ីវិល អគ្គស្នងការនគរបាលជាតិ សាលាខេត្តព្រះសីហនុ កំពង់ផែស្វយ័ត និងក្រសួង ស្ថាប័ននានា សម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា បំពេញបេសកកម្មក្នុង-ក្រៅប្រទេស ស្នើសុំ អាហារូបករណ៍ វគ្គបណ្តុះបណ្តាល និងការ រៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ព្រឹទ្ធសភាកំពុងអនុវត្តការសាងសង់ អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ជាជំនួយពីរដ្ឋាភិបាលសាធារណរដ្ឋ ប្រជាមានិតចិន<br>- សិក្សាអំពីគម្រោងប្លង់កសាងអគារសាល ប្រជុំថ្មី<br>- សហប្រតិបត្តិការជាមួយដៃគូរ ដើម្បី អភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ ស្ថាប័ន<br>- ព្រឹទ្ធសភា បានផលិត និងផ្សព្វផ្សាយ ខ្សែវីដេអូ ស្តីពីសមិទ្ធផលឆ្នាំទី៤ របស់ ព្រឹទ្ធសភា នីតិកាលទី៣ ។ | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារ ផ្សេងៗចំនួន៣,២១៤ច្បាប់<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានធ្វើលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការ គ្រប់គ្រងមន្ត្រីរាជការសរុបចំនួន២៨៨ច្បាប់<br>- បានកសាងសេចក្តីព្រាងស្តីពីគោលការណ៍តែង តាំងមន្ត្រីរាជការឲ្យកាន់មុខតំណែង<br>- ប្រជុំការងារស្តីពីសេចក្តីព្រាងប័ណ្ណស្នើថវិកាថ្មី<br>- បានវាយតម្លៃបុគ្គលិកជាប់កិច្ចសន្យា និងមន្ត្រីរាជការ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ ដែលមានស្នាដៃសម្រាប់ឆ្នាំ២០១៥<br>- បានវាយតម្លៃការអនុវត្តផែនការប្រតិបត្តិសម្រាប់ ត្រីមាសទី១ និងឆមាសទី១ ឆ្នាំ២០១៦<br>- រៀបចំកាត់ឯកសណ្ឋានជូនមន្ត្រីរាជការឆ្នាំ២០១៦<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស :<br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេស ចំនួន៣៩វគ្គ មានសិក្ខាកាមចូលរួមចំនួន៤៥៥នាក់ |

| | |
|---|---|
| | និងក្រៅប្រទេសចំនួន០៨លើក មានសិក្ខាកាមចូលរួមចំនួន២១នាក់<br>- សិក្ខាសាលាក្នុង និងក្រៅប្រទេសចំនួន០៨លើក មានសិក្ខាកាមចូលរួមសរុបចំនួន១៨៧នាក់<br>- កសាងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រយៈពេល០៥ឆ្នាំ (២០១៧-២០២១)<br>- កសាងឯកសារជំនួយស្មារតីមគ្គុទេសក៍សម្រាប់កម្មវិធីទស្សនកិច្ចសិក្សានៅព្រឹទ្ធសភា<br>- សិក្សារៀបចំសេចក្តីព្រាង និងសេចក្តីសម្រេចស្តីពីការគ្រប់គ្រងមន្ត្រីរាជការទៅសិក្សានៅក្រៅប្រទេស<br>+**ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**:<br>- រៀបចំកសាងផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិលព្រឹទ្ធសភា(២០១៧-២០១៩)<br>- រៀបចំថវិកាតាមកម្មវិធីឆ្នាំ២០១៦ និងការរៀបចំគម្រោងថវិកា ឆ្នាំ២០១៧<br>- បានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិតាមគោលការណ៍កំណែទម្រង់ថវិកា<br>- រៀបចំស្នើសុំឥណទានបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភប្រចាំខែជូនបុគ្គលិកជាប់កិច្ចសន្យា និងតម្លៃសន្ទស្សន៍បៀវត្សពី១,៥២០រៀល ទៅ១,៧០០រៀល<br>- ទូទាត់ថ្លៃទិញសម្ភារការិយាល័យ អនាម័យប្រចាំត្រីមាសទី២ឆ្នាំ២០១៦ ឯកសណ្ឋានមន្ត្រីរាជការបោះពុម្ពព្រឹត្តិបត្រត្រីមាសទី៤ឆ្នាំ២០១៥ និងប្រចាំខែកុម្ភៈ ដល់ខែមិថុនា ឆ្នាំ២០១៦ និងថ្លៃទិញប្រេងឥន្ធនៈ |

- បានដោះស្រាយសំណើនានាជូនព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៦៤៧លើក
- ប្រគល់ និងទទួលសម្ភារផ្សេងៗ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានចំនួន២២សំណើ
- រៀបចំសម្អាត តុបតែងសាល កន្លែងប្រារព្ធពិធី និងផ្ដល់សេវាបម្រើភេសជ្ជៈ ផ្គត់ផ្គង់សម្ភារអនាម័យចំនួន១៤៧លើក មានអ្នកចូលរួមចំនួន៣,៧៧២នាក់
- បានផ្គត់ផ្គង់សម្ភារអនាម័យ ការិយាល័យ និងភេសជ្ជៈចំនួន២២៨សំណើ
- ថតចម្លងឯកសារបានចំនួន១៨០សំណើ និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន១៦៩ក្បាល អស់ក្រដាសចំនួន៦៥,៤៧៥សន្លឹក ព្រមទាំងផ្ដល់សេវាដឹកជញ្ជូនក្នុងរាជធានីចំនួន៣៤២នាក់ ស្មើនឹង២៧២លើក
- បានធ្វើរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០១៥
- ការងារលទ្ធកម្មសាធារណៈប្រចាំឆ្នាំ (សំលៀកបំពាក់ សម្ភារការិយាល័យ បោះពុម្ព ប្រេងឥន្ធនៈ និងរថយន្ត

+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រឹង និងទន់:

- បន្តតាមដាន សហការ និងត្រួតពិនិត្យដំណើរការការដ្ឋានសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា
- ចាត់ចែងការដ្ឋានចិន និងប្លង់អគារថ្មី ប្លង់កែលម្អសាលប្រជុំចាស់
- ចាត់ចែងរៀបចំបន្ទប់ការិយាល័យ ឯកសណ្ឋាន និងរបបផ្សេងៗជូនសមាជិកព្រឹទ្ធសភាថ្មី
- រៀបចំទិន្នន័យ និងប្លង់: អគ្គិសនី លូទឹក ប្រព័ន្ធ

| | |
|---|---|
| | ទឹកស្អាត អនុវត្តន៍គម្រោងជុំវិញបណ្ណាល័យក្នុងបរិវេណអគារក្រហម ផ្លូវថ្នល់ ចិញ្ចើមថ្នល់ អគារសាលប្រជុំពេញអង្គ និងអនុវត្តន៍គម្រោងជួសជុលបន្ទប់ទឹក<br>- ការលើកកម្ពស់ការងារបរិស្ថាន និងការកែលម្អសួនច្បារ<br>- ពង្រីកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទៅក្នុងការដ្ឋានការងារប្រចាំថ្ងៃ និង E-Library<br>- បំពាក់កុំព្យូទ័រ ម៉ាស៊ីនព្រីនព័រណ៌ចំនួន០៦គ្រឿង<br>- ជួសជុល កែលម្អ លាប បាំងបន្ទប់កញ្ចក់អាលុយមីញ៉ូម ប្តូរពិដាន បិទប្រឡោះការពារ ដើម្បីកុំឲ្យសត្វប្រចៀវហើរចូលសាលប្រជុំពេញអង្គ អគារបណ្ណាល័យនាយកដ្ឋានរដ្ឋបាល ព្រមទាំងតបណ្តាញទឹក បណ្តាញលូទឹក ស្តារលូ និងបណ្តាញអគ្គិសនីនៅការដ្ឋានសាងសង់អគារការិយាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា<br>- តម្លើងធ្នើរដែកដាក់ឯកសារនៅនាយកដ្ឋានព័ត៌មាន និងតម្លើងរោងបណ្តុះកូនឈើនៅនាយកដ្ឋានរដ្ឋបាល ព្រមទាំងតម្លើងម៉ាស៊ីនកាត់សៀវភៅ ដើម្បីសម្រួលដល់ការបញ្ចូល និងស្កេនឯកសារចូលក្នុងកម្មវិធី E-Library<br>- សង់រោងធ្វើចំណតរថយន្តបន្ថែម នៅក្បែររោងចតរថយន្តដើមជ្រៃ និងចាក់សាប គូសគំនូស និងរៀបខឿនជុំវិញចំណតរថយន្តថ្មី<br>- ទិញកៅអីពូកជើងថ្មីដាក់នៅសាលបណ្ណាល័យចំនួន២០០គ្រឿង និងបិទលេខកូដសម្ភារការិយាល័យ និងសម្ភារផ្សេងៗចំនួន៥២គ្រឿង |

| | |
|---|---|
| | - ជួសជុល ខាត់ លាប និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច តុសាតាំង ក្រណាត់កៅអីក្បាច់ កៅអីពូក ដៃទ្វារ សោទ្វារ ទ្វារឈើក្បាច់ចំនួន ១,០៥១គ្រឿង/វង់ បន្ទប់ទឹក និងបណ្តាញទឹកចំនួន ៦៤គ្រឿង/បន្ទប់<br>- សហការរៀបចំ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំចំនួន៦៤លើក និងរៀបចំសណ្តាប់ធ្នាប់រថយន្តគ្រប់ប្រភេទនៅក្នុងព្រឹទ្ធសភាចំនួន១២៦លើក<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork, Internet, Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីUnicode និងSet up កម្មវិធីសរុបចំនួន ២៤៩គ្រឿង ។ រៀបចំមាតិកា និង Upload រូបភាពសកម្មភាពការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា គេហទំព័រព្រឹទ្ធសភាសរុបចំនួន៧៤២ប្រធានបទ<br>+ការងារផ្សេងៗ:<br>- រៀបចំ និងចងក្រងសៀវភៅជាភាសាអង់គ្លេស ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្ររាជកិច្ចចំនួន ៤,៣៨៣ក្បាល ព្រឹត្តិបត្រចំនួន៧៣៨ច្បាប់ កាសែតចំនួន៧២ចំណងជើង និងដាក់លេខកូដសៀវភៅថ្មីចំនួន៨៧៩ក្បាល<br>- បញ្ចូលឯកសារ-សៀវភៅច្បាប់ និងជំនាញផ្សេងៗចូលក្នុងបណ្ណាល័យអេឡិចត្រូនិចចំនួន៥០ក្បាល<br>- ផលិតខ្សែVideo សមិទ្ធផលឆ្នាំទី៤ របស់ព្រឹទ្ធសភានីតិកាលទី៣ និងបានផ្សព្វផ្សាយទៅតាមបណ្តាសារព័ត៌មាន និងស្ថានីយទូរទស្សន៍នានា ។ |

## II.ទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦

### ១.មុខងារនីតិកម្ម:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គ ប្រជុំវិសាមញ្ញព្រឹទ្ធសភា

-ការបង្កើតគណៈកម្មការពិសេស ដើម្បីពិចារណាវិសោធនកម្មរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុង ច្បាប់លក្ខន្តិកៈសមាជិកព្រឹទ្ធសភា ច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឬច្បាប់ពិសេសណាមួយ

-រៀបចំកម្មវិធីនីតិកម្មរបស់ស្ថាប័ន កម្មវិធីផ្សព្វផ្សាយច្បាប់សំខាន់ៗ និងវិធីឆ្លើយឆ្លងសាធារណជន អំពីការងារនីតិកម្ម

-ការផ្លាស់ប្តូរបទពិសោធន៍ខាងការធ្វើច្បាប់ សិក្ខាសាលា តុមូល ការពិគ្រោះយោបល់ សន្និសីទ និងការផ្លាស់ប្តូរបទពិសោធន៍ជាមួយសភាដទៃ ។

### ២.មុខងារតំណាង :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត-ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

### ៣.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត-ក្រុង

-ដំណើរការកម្មវិធីតាមដានការអនុវត្តច្បាប់ គោលនយោបាយនៅថ្នាក់ជាតិ-ក្រោមជាតិ និងការកសាងបទដ្ឋានក្រោមច្បាប់

-ដំណើរការស្រាវជ្រាវ វិភាគ សំយោគ វាយតម្លៃ និងសន្និដ្ឋាន ដើម្បីផ្តល់អនុសាសន៍

-ការសិក្សាលើរបាយការណ៍ផ្តល់ដោយរាជរដ្ឋាភិបាល និងក្រសួងមានសមត្ថកិច្ច និងការផលិតនូវរបាយការណ៍ស្តីពីការតាមដានមើលការអនុវត្តច្បាប់ ។

### ៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ

-បដិសណ្ឋារកិច្ចគណៈប្រតិភូបរទេស និងអង្គទូត ក្នុងនាមប្រមុខរដ្ឋស្តីទី ប្រធាន-អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការ

-ត្រៀមរៀបចំកម្មវិធីជួបប្រាស្រ័យជាមួយក្រសួង ដើម្បីទទួលព័ត៌មានអំពីសហប្រតិបត្តិការអន្តរជាតិ តាមវិស័យ និងការអនុវត្តកិច្ចព្រមព្រៀងផ្សេងៗ

-ការចូលរួមក្នុងគណៈប្រតិភូអន្តរសភា គណៈប្រតិភូរាជរដ្ឋាភិបាល និងចូលរួមអនុវត្តន៍សហប្រតិបត្តិការ និងបច្ចេកទេសរវាងសភា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា រួមទាំងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

+ដំណើរទស្សនកិច្ចជាមិត្តភាព និងជាផ្លូវការរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា នៅសភាបរទេសជាមិត្ត

+ ចូលរួមប្រជុំ AIPA, IPU, APF, CLV

+ ចូលរួមសន្និសីទ សិក្ខាសាលា តុមូល ថ្នាក់ជាតិ តំបន់ និងអន្តរជាតិ

-ការផ្តល់សច្ចាប័នលើសន្និសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀង

-ការតាមដានមើលការអនុវត្តអនុសាសន៍របស់អង្គការអន្តរជាតិពាក់ព័ន្ធវិស័យសិទ្ធិមនុស្ស

-ការផ្លាស់ប្តូរគណៈប្រតិភូទ្វេភាគីជាមួយសភានៃប្រទេសជាមិត្ត និងការផ្លាស់ប្តូរបទពិសោធន៍ត្រឹមកម្រិតគណៈកម្មការជំនាញ

-ការចុះហត្ថលេខា និងការអនុវត្តអនុស្សារណៈនៃកិច្ចសហប្រតិបត្តិការអន្តរសភា (រុស្ស៊ី វៀតណាម កូរ៉េ ឥណ្ឌូនេស៊ី) និងកម្មវិធីប្រចាំឆ្នាំ(បារាំង ហ្វីលីពីន) ព្រមទាំងការចុះហត្ថលេខារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយប៉ាគីស្ថាន និងឥណ្ឌា

-ការចូលរួមកម្មវិធីបុណ្យជាតិនៃប្រទេសជាមិត្ត (សារលិខិត និងកន្រ្តកផ្កា ការរំលែកទុក្ខ និងប័ណ្ណជូនពរប្រចាំឆ្នាំ) និងពិធីជប់លៀងច្រើនកម្រិត ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

+ការងារគ្រប់គ្រងបុគ្គលិកៈ

-ត្រៀមរៀបចំផ្តល់គ្រឿងឥស្សរិយយសប្រចាំឆ្នាំ

-រៀបចំការតែងតាំង ផ្ទេរ សាកល្បង តាំងស៊ប់ បញ្ចប់មុខតំណែង និងការចូលនិវត្តន៍

-ការងារតម្លើងថ្នាក់សន្ទស្សន៍ តម្លៃ បៀវត្ស និងផលប្រយោជន៍ផ្សេងៗ

-ការជានាអនុវត្តច្បាប់ អនុវត្តវិន័យ គោលការណ៍ លិខិត និងបទដ្ឋាន

-ការងារសោធននិវត្តបាត់បង់សមត្ថភាពពលកម្ម ការងារសមាគមសង្គហៈសង្គ្រោះ

-រៀបចំកម្មវិធីពិគ្រោះយោបល់តាមជំនាញ

+ការងារបណ្តុះបណ្តាលធនធានមនុស្សៈ

-ការរៀបចំទទួលអ្នកឯកទេសមកពីអង្គការ និងសភានានា ដើម្បីផ្តល់ការបណ្តុះបណ្តាលការងារគ្រប់គ្រងបុគ្គលិក និងការងារបច្ចុប្បន្នភាពរចនាសម្ព័ន្ធ

-ការរៀបចំដំណើរទស្សនកិច្ចសិក្សាទៅកាន់សភានានា

-ត្រៀមចូលរួមសិក្ខាសាលា ប្រជុំតុមូល បណ្តុះបណ្តាលសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងវគ្គបណ្តុះបណ្តាលផ្សេងៗ

-ការបណ្តុះបណ្តាលជំនាញចាំបាច់ សម្រាប់តម្រូវការរបស់អង្គភាព និងការបណ្តុះបណ្តាលទូទៅអំពីការដឹកនាំ និងការគ្រប់គ្រង

-ការស្វែងរកអាហារូបករណ៍ក្នុង/ក្រៅប្រទេស ដើម្បីលើកកម្ពស់ចំណេះដឹង តាមរយៈការលើកកម្ពស់សញ្ញាបត្រ

-ការបង្កើនសមត្ថភាពខាងការស្រាវជ្រាវរបស់គ្រប់អង្គភាព និងមន្ត្រីដែលបានបណ្តុះបណ្តាល

ខាងការស្រាវជ្រាវ

-ការបណ្តុះបណ្តាលភាសាបរទេសដូចជាបារាំង អង់គ្លេស ចិន ជប៉ុន ដើម្បីបង្កើនសមត្ថភាពទំនាក់ទំនងស្រាវជ្រាវ និងអភិវឌ្ឍន៍ស្ថាប័ន

-កសាងគោលការណ៍ណែនាំអំពីការរៀបចំដំណើរទស្សនកិច្ចសិក្សា វេទិកា និងការពិគ្រោះយោបល់សាធារណៈ

**+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :**

-ការកសាងថវិកាឆ្នាំ២០១៧ លើមូលដ្ឋាននៃការកសាងក្របខណ្ឌយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងដំណើរការអង្គភាពថវិកាតាមកម្មវិធីចាប់ពីឆ្នាំ២០១៦

-ការចូលរួមដោយសកម្មក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់នានា តាមរយៈការកសាង ការធ្វើបច្ចុប្បន្នភាព លិខិតបទដ្ឋាន គោលការណ៍គោលនយោបាយនានា ដើម្បីជានាការអនុវត្តសមស្របក្នុងការដឹកនាំ និងគ្រប់គ្រងទូទៅសេវាផ្សេងៗ និងហិរញ្ញវត្ថុ (ប្រាក់បៀវត្ស និងផលប្រយោជន៍ គោលនយោបាយលើកទឹកចិត្ត....)

**+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង-ទន់ ព្រមទាំងការងារផ្សេងៗ:**

-ការសិក្សាដើម្បីឆ្ពោះទៅកាន់ការបង្កើតPBO

-ការសិក្សាអំពីបរិបទបរិស្ថាន ការថែទាំអគារ ហេដ្ឋារចនាសម្ព័ន្ធទូទៅ ការកសាង និងគ្រប់គ្រងទិន្នន័យទូទៅ កែលម្អសួនច្បារ និងទីធ្លា

-ការកសាងក្របខ័ណ្ឌយុទ្ធសាស្ត្រតាមវិស័យ: ធនធានមនុស្ស ការស្រាវជ្រាវ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ការប្រាស្រ័យទាក់ទង/ទំនាក់ទំនងសាធារណៈ អង្គភាពថវិកា និងការចំណាយតាមកម្មវិធី ការបណ្តុះបណ្តាលជំនាញនីតិកម្ម បណ្ណាល័យ បណ្ណសារដ្ឋានទំនើប ការបន្តកែលម្អសាលប្រជុំ កម្មវិធីថែទាំ និងជុសជុលអគារ ផ្លូវថ្នល់ បណ្តាញទឹក អគ្គិសនី និងចូលរួមកសាងអគារថ្មី (ជំនួយចិន)

-វិធានការឆ្ពោះទៅកាន់បណ្ណាល័យ និងបណ្ណសារដ្ឋានទំនើប និងអនុវត្តកម្មវិធី E-បណ្ណាល័យ

-វិធានការកែលម្អ Studio និងប្រព័ន្ធកាមេរ៉ាក្នុងសាលប្រជុំពេញអង្គ

-វិធានការបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៅក្នុងការងារប្រចាំថ្ងៃ ដើម្បីកាត់បន្ថយក្រដាសជាជំហានៗ និងបង្កើតប្រើប្រាស់ Program និងSoftware សមស្របតាមតំរូវការរបស់អង្គភាពនីមួយៗ និងការអភិវឌ្ឍគេហទំព័រ និងបណ្តាញសង្គម Line, Facebook, Telegram...(កំរិតស្ថាបន័ គណៈកម្មការ អគ្គនាយកដ្ឋាន និងនាយកដ្ឋាន)

-វិធានការបង្កើនសមត្ថភាព ការនាំពាក្យរបស់ស្ថាប័នទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ គុណភាពនៃការផ្សព្វផ្សាយ និងការបោះពុម្ពសព្វសារពើ

-វិធានការបង្កើនសមត្ថភាពផលិតខ្សែវីដេអូ និងទំនាក់ទំនងជាមួយបណ្ដាវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន

-វិធានការអភិវឌ្ឍទំនាក់ទំនងសាធារណៈ៖ បច្ចុប្បន្នភាព ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃការអភិវឌ្ឍទំនាក់ទំនងសាធារណៈ

-ការបង្កើតគេហទំព័ររបស់គណៈកម្មការជំនាញទាំង ១០ និងការផលិតTV- online របស់ព្រឹទ្ធសភា

-ការសិក្សាអំពីការបន្ថែមលទ្ធភាព ធនធាន មធ្យោបាយ ហិរញ្ញវត្ថុ ដើម្បីពង្រឹងភាពស្អិតរមួត និងភាពរលូននៃប្រព័ន្ធការងារពហុសេវា ពហុវិស័យ នៅគ្រប់អង្គភាព និងគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល ល្បឿន ទំនុកចិត្ត ជំនឿរបស់អតិថិជន (ទាន់ចិត្ត/ត្រូវចិត្ត) ។

## III.សេចក្តីសន្និដ្ឋាន

ក្នុងឆមាសទី១នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានការងារមមាញឹកគ្រប់ការដ្ឋានវិស័យ និងគ្រប់យន្តការអង្គភាព ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាគ្រប់ប្រភេទឲ្យកាន់តែល្អ និងមានគុណភាពសម្រាប់អតិថិជន ។ ការបំពេញភារកិច្ច បានឆ្លុះបញ្ចាំងឲ្យឃើញនូវលទ្ធផលការងារសំខាន់ៗលើគ្រប់ការដ្ឋានដែលបានដំណើរការដោយរលូន និងមានលទ្ធផលជាផ្លែផ្កាច្រើនជាងពេលមុនៗ ។

+រយៈពេល៦ខែនេះ ថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់លើការងារពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ និងក្រុមនានា ដើម្បីលើកកម្ពស់មុខងារនីតិកម្ម មុខងារតំណាង មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ ។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ មានថាមពលកាន់តែមមាញឹកហើយមានលទ្ធផលជាផ្លែផ្កា ជាគុណប្រយោជន៍ដល់ជាតិ និងស្ថាប័ន ។ វិទ្យាស្ថានសភាកម្ពុជា បានបើកលទ្ធភាពថ្មី ដើម្បីសមាជិកទទួលបានទស្សនៈ និងបទពិសោធន៍ថ្មីក្នុងការងារសភា ។ ការអភិវឌ្ឍស្ថាប័ន តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានកាន់តែទំនើប ដើម្បីផ្សព្វផ្សាយព័ត៌មានជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា មន្ត្រីរាជការព្រមទាំងមហាជនទាំងអស់ឲ្យយល់ដឹងអំពីដំណើរការវិវត្តការងាររបស់ព្រឹទ្ធសភា បានអនុវត្តន៍ល្អ និងទូលំទូលាយជាងមុន ។ គោលការណ៍ និងគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាលចំនួន២០ចំណុច បានបន្តនូវភាពអនុគ្រោះថ្មីៗជារួមដល់ដំណើរទៅមុខរបស់ស្ថាប័ន ដែលត្រូវចូលអនុវត្តន៍កំណែទម្រង់ខាងរដ្ឋបាល និងកំណែទម្រង់ខាងហិរញ្ញវត្ថុកាន់តែជ្រាលជ្រៅ ។

ភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការស្តីទី**

ឡោក-ឆាយ